# ស្ថានភាពអតិផរណានៅខែធ្នូ ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែធ្នូ បានថយចុះ **០,៥%** ធៀបនឹងខែមុន ប៉ុន្តែកើនឡើង **១,៦%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

ស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៨នេះ នៅតែបន្តស្ថិតក្នុងកម្រិតមួយល្អប្រសើរ ពោលគឺក្នុងអត្រាមួយដែលអាចគ្រប់គ្រងបាន។ **ស្ថានភាពអតិផរណាមធ្យមប្រចាំឆ្នាំមានអត្រា *២,៥%* ពោលគឺទាបជាងឆ្នាំ២០១៧ ដែលមានអត្រា *២,៩%* ដោយសារការថមថយកំណើននៃសន្ទស្សន៍ថ្លៃក្រុមទំនិញម្ហូបអាហារ និងសន្ទស្សន៍ថ្លៃក្រុមទំនិញការដឹកជញ្ជូន ដែលមានមេគុណប្រមាណជាងពាក់កណ្តាលនៃទំហំកន្ត្រកទំនិញសរុប (៥៧ភាគរយ)**។ សង្កេតឃើញថា ក្នុងឆ្នាំ២០១៨នេះស្ថានភាពអតិផរណាមធ្យមប្រចាំឆ្នាំនៃសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹងមានអត្រា ២,៥% ទាបជាងឆ្នាំ២០១៧កន្លងទៅ ដែលមានអត្រា ៣,៤% ដែលក្នុងនោះសាច់ ត្រីស្រស់ និងបន្លែ មានការថមថយកំណើនគួរឱ្យកត់សម្គាល់។ រីឯស្ថានភាពអតិផរណាមធ្យមប្រចាំឆ្នាំនៃសន្ទស្សន៍ថ្លៃក្រុមទំនិញការដឹកជញ្ជូនមានអត្រា ២,៩% ទាបជាងឆ្នាំ២០១៧កន្លងទៅដែលមានអត្រា ៤,១% ដោយសារការថមថយកំណើននៃមុខទំនិញមួយចំនួនដូចជា ប្រេងសាំង និងម៉ាស៊ូត។

**តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%)**

| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **-០,៥** | **+១,៦** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | -០,១ | +១,៩ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +០,៥ | +៥,៦ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -០,១ | +២,៨ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -០,៦ | +០,៤ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | -០,១ | +០,៤ |
| ៦-សុខាភិបាល | +០,២ | +២,០ |
| ៧-ការដឹកជញ្ជូន | -៣,៦ | -២,៤ |
| ៨-គមនាគមន៍ | -០,៣ | -០,៦ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៤ | +០,៨ |
| ១០-ការសិក្សា | ០,០ | +០,៤ |
| ១១-ភោជនីយដ្ឋាន | -០,៣ | +៥,២ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,៤ | +០,៦ |

| តារាង២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | តុលា | វិច្ឆិកា | ធ្នូ | តុលា | វិច្ឆិកា | ធ្នូ |
| អង្ករ | +០,២ | -០,៣ | +០,៣ | +២,៩ | +២,៣ | +២,៤ |
| សាច់គោ | -០,១ | ០,០ | +០,២ | +២,២ | +១,៨ | +១,២ |
| សាច់មាន់ | +០,២ | +០,៤ | +០,៤ | +១,៧ | +២,១ | +៣,២ |
| សាច់ទា | +០,៧ | +០,៣ | -០,៣ | +២,១ | +២,១ | +១,៥ |
| សាច់ជ្រូក | -០,៦ | -១,៨ | -០,៣ | +៣,៥ | +១,២ | +១,៥ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,១ | -០,៧ | +០,១ | +៤,១ | +២,២ | +២,៣ |
| ក្នុងនោះត្រីស្រស់ | ០,០ | -១,១ | +០,១ | +៤,៣ | +១,៧ | +១,៨ |
| ផ្លែឈើ | +០,៨ | +០,១ | -០,៣ | +២,៥ | +៣,០ | +១,៨ |
| ផ្លែឈើស្រស់ | +០,៩ | +០,១ | -០,៣ | +២,៥ | +៣,០ | +១,៧ |
| បន្លែ | +០,៥ | -០,៩ | -០,៨ | +៥,៩ | +៤,៩ | +៣,៥ |
| បន្លែជាស្លឹក | +១,៥ | -១,៤ | -១,០ | +១០,៦ | +៧,៧ | +៤,៩ |
| បន្លែជាផ្លែ | -០,៤ | -០,៦ | -១,២ | +៥,៤ | +៦,៤ | +៥,៤ |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

ដោយឡែក បើក្រឡេកមើលស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៨ របស់ប្រទេសជាដៃគូពាណិជ្ជកម្មជិតខាងវិញនោះ សង្កេតឃើញថា ស្ថានភាពអតិផរណានៅប្រទេសថៃមានអត្រាខ្ពស់ជាងឆ្នាំ២០១៧ ដោយសារការកើនឡើងនៃថ្លៃប្រេងលក់រាយក្នុងស្រុក និងថ្លៃឧស្ម័នប្រេងរាវ (LPG) ក្នុងអំឡុងត្រីមាសទី២ និងទី៣ (ស្របគ្នានឹងការកើនឡើងថ្លៃប្រេងឆៅពិភពលោក) ដែលនាំឱ្យមានការកើនឡើងនៃថ្លៃថាមពល (យោងតាម÷ Monetary Policy Report by quarter, Bank of Thailand)។ រីឯ ស្ថានភាពអតិផរណានៅប្រទេសវៀតណាមមានអត្រា ៣,៦% ប្រហាក់ប្រហែលគ្នាទៅនឹងឆ្នាំ២០១៧ ដែលអត្រានេះគឺស្ថិតនៅក្នុងកម្រិតប្រហាក់ហែលទៅនឹងគោលដៅដែលធនាគារកណ្តាលនៃប្រទេសវៀតណាមបានកំណត់ (៤,០%)។

| តារាង ៣÷ អត្រាអតិផរណារយៈពេល ៥ឆ្នាំចុងក្រោយ របស់ប្រទេសកម្ពុជា និងប្រទេសជិតខាង | | | | | |
|---|---|---|---|---|---|
| អតិផរណាថ្លៃទំនិញ (មធ្យមប្រចាំឆ្នាំ) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| កម្ពុជា | ៣,៩% | ១,២% | ៣,០% | ២,៩% | ២,៥% |
| ថៃ | ១,៩% | -០,៩% | ០,២% | ០,៧% | ១,១% |
| វៀតណាម | ៤,១% | ០,៦% | ២,៧% | ៣,៥% | ៣,៦% |
| *ប្រភពទិន្នន័យ÷ វិទ្យាស្ថានជាតិស្ថិតិ (NIS), គេហទំព័រ www.tradingeconomics.com* | | | | | |

| តារាង ៤÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | |
|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | ២០១៨ | | |
| | តុលា | វិច្ឆិកា | ធ្នូ | តុលា | វិច្ឆិកា | ធ្នូ |
| ប្រទេសកម្ពុជា | 2.1 | 2.3 | 2.2 | 3.1 | 2.5 | 1.6 |
| ប្រទេសវៀតណាម | 3.0 | 2.6 | 2.6 | 3.9 | 3.5 | 3.0 |
| ប្រទេសថៃ | 0.9 | 0.99 | 0.78 | 1.2 | 0.9 | 0.4 |
| ប្រទេសម៉ាឡេស៊ី | 3.7 | 3.4 | 3.5 | 0.6 | 0.2 | 0.2 |
| ប្រទេសឥណ្ឌូនេស៊ី | 3.6 | 3.3 | 3.6 | 3.2 | 3.2 | 3.1 |
| ប្រទេសហ្វីលីពីន | 3.5 | 3.3 | 3.3 | 6.7 | 6.0 | 5.1 |
| ប្រទេសចិន | 1.9 | 1.7 | 1.8 | 2.5 | 2.2 | 1.9 |
| ប្រទេសកូរ៉េខាងត្បូង | 1.8 | 1.3 | 1.5 | 2.0 | 2.0 | 1.3 |
| ប្រទេសជប៉ុន | 0.2 | 0.6 | 1.0 | 1.4 | 0.8 | 0.3 |

ប្រភពទិន្នន័យ
(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

## <u>កំណត់សម្គាល់</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបតំរូវចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)


***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧  ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*


*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*